ទស្សនាវដ្តី លេខ ២

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តបទ្មា សង្កាត់លេខ ៦

ភ្នំពេញ

ក 125

125

# មាតិការឿង


| | | |
|---|---|---|
| បណ្ណាធិការ . . . . . . | វិចារណកថា | ទំព័រ ១ |
| ព្រះមហាសុខ . . . . . . | ពុទ្ធទស្សនៈ (ត) | ,, ៤ |
| លោកស្រី-អ៊ូ . . . . . | ដំណើរសាសនា | ,, ៨ |
| . . . . . . | ការចូលកាន់មរណៈសញ្ញា | ,, ១៥ |
| . . . . . . | សេចក្ដីកត់ហេតុមហាសន្និបាត ,, | ១៦ |
| ម. បុទ្រី . . . . . . . | និទានព្រះសុន្ទរសមុទ្ទត្ថេរ (តចប់) | ១៨ |
| មហាមាស-ចន . . . . . | ប្រវត្តិសង្ខេបនៃនាលន្ទា ,, | ,, ២៣ |
| លោក ព៉យ-ប៊ុក . . . . | រឿងតុក្កតាធ្វើពីទធិជាតិ (ត) | ,, ២៧ |
| លោកតៃ-ជុន . . . . . | ជ័យប្រាជ្ញ (ត) | ,, ២៩ |
| លោកសួន-ស៊ិន . . . . | បុណ្ណកុមារ (ត) | ,, ៣១ |
| . . . . . . | ប្រវត្តិក្មេងកំព្រា | ,, ៣៤ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលឡៀជាវ


សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# វិចារណកថា

## ពុទ្ធសករាជ ២៥០០

យើងធ្លាប់ឮមកហើយថា ដល់ពាក់កណ្ដាលសាសនា ព្រះពុទ្ធសាសនានឹងបានរុងរឿងឡើងវិញ ហើយជនទាំងឡាយក្នុងពិភពលោកត្រូវរស់នៅជាសុខយ៉ាងក្រៃលែង ថែមទាំងមានសម្បត្តិគ្រប់គ្រាន់ស្មើមុខគ្នា ទាំងអស់មិនមានការព្រួយលំបាក ចំពោះការរកស៊ីចិញ្ចឹមជីវិតឡើយ

បើតាមទំនាយដែលសព្វថ្ងៃស្ទើរតែក្លាយទៅជាពាក្យធម្មតាទៅហើយនោះ តើយើងអាចជឿបានថា “ព្រះពុទ្ធសាសនានឹងបានរុងរឿង ហើយប្រជាជនក្នុងលោក ពិតជាបានទទួលសេចក្ដីសុខ នឹងសម្បត្តិស្មើភាគគ្នាបានទេ?” ឥឡូវពាក់កណ្ដាលសាសនាក៏ចេះកកិលចូលមកជិតហើយ ៗ សាសនាដូចជាពុំទាន់ឃើញចំរើនអ្វីប៉ុន្មាន អ្នកមានឋានៈថោកទាបនឹងទន់ខ្សោយក៏ចេះតែកើតមានឡើងជាលំដាប់ ៗ

ហេតុដូចម្ដេច ក៏បានជាយើងខ្ញុំហ៊ានពោលបែបនេះ បើសព្វថ្ងៃយើងគេបានឃើញច្បាស់នឹងមំសចក្ខុទៅហើយ ថាប្រជាជនពិភពលោកកំពុងតែងាកមករក ការប្រតិបត្តិខាងព្រះពុទ្ធសាសនា ហើយចំពោះអ្នកប្រាជ្ញវិទ្យាសាស្ត្រទៀតសោត កំពុងតែស្រាវជ្រាវយកធាតុបរមាណូមកបង្កើតជាប្រយោជន៍ដល់សាធារណជនទូទៅ

ហើយមហាអំណាចទាំងឡាយ ក្នុងលោកក៏កំពុងតែពោលថា ស្វែងរកសន្តិភាពនឹងយុត្តិធម៌ ដើម្បីពិភពលោក ។

ពាក្យនេះ ជាសំដីដែលយើងធ្លាប់ឮ-ឃើញហើយ ធ្លាប់ជឿថាពិតមែន ! តែមានជនបំពួកខ្លះគេនៅជឿថាជាសំដីលាយឡំ ដោយការក្លែងក្លាយនៅឡើយ

តាមសំដីជនមួយចំណែកទៀតដែលគេជឿច្បាស់ថាជាអ្នកពុទ្ធជនសុទ្ធសាតនោះ គេពោលពាក្យមានន័យផ្ទុយពីនេះទៅវិញគឺថា "ពាក់កណ្តាលសាសនាជាវេលា ដែលពុទ្ធសាសនារេះតែអន់ថយទៅ តែមានកើតភិក្ខុអ-លជ្ជីនឹងពុទ្ធជនក្លែងក្លាយច្រើន ហើយមាន មនុស្សដែល ត្រូវ ធ្លាក់ ខ្លួន ជា ខ្ញុំកញ្ជះគេក៏រឹតតែច្រើនទៅទៀត ។ ចុះហេតុ ម្តេច បាន ជា គេ ហ៊ាន ពោល ដូចនោះ? ព្រោះថា ! អ្នកកាន់ព្រះពុទ្ធសា-សនាមានចំនួនច្រើនមែន តែច្រើនជាមនុស្សដែលត្រូវនឹងពាក្យបូរាណពោលថា "បុណ្យក៏ធ្វើ ឈើក៏កាប់ សត្វក៏សម្លាប់ សីលក៏រក្សា" ពាក្យនេះជាពាក្យពិត ហើយថែមទាំងមានសារៈគួរឲ្យគេពិចារណាណាស់ ។

យើងដឹងច្បាស់ទៅទៀតថា តើមនុស្សដែលសមនឹងលក្ខណៈនេះច្រើនជាមនុស្សបែបណា? ។ ក្នុងកម្ពុជៈយើង ខ្ញុំពោលដោយស្មានទៅចុះថា ច្រើនតែជាមិត្តរបស់ខ្ញុំ ដែលបានក្រេបរសជាតិព្រះពុទ្ធសាសនា ច្រើនជាងគេ "សូមមិត្តអភ័យទៅចុះ ពាក្យនេះមិនមែនជាពាក្យបន្តុះបង្អាប់ទេ គឺជាពាក្យពិតតាមចក្ខុលោកជន" ។

ភិក្ខុបួសក្នុងសាសនា សម័យនេះមិនសូវមានន័យ ប្រកបដោយ ការលះបង់ទេ ច្រើនតែស្វែងរកប្រយោជន៍ដើម្បីការរស់នៅទៅអនាគត ។ សូម

បង្ហាញ៖ ឧទាហរណ៍នៅប្រទេសថៃ ថា ភិក្ខុជាតិថៃ ស្ទើរតែគង់រួមគ្នាមួយនឹងនារីបានខ្ទុះទៅហើយ ចុះភិក្ខុជាតិយើងវិញបែបណា? មិនទាន់ដល់ថ្នាក់ហ្នឹងទេ តែគួរប្រយ័ត្នឲ្យហើយទៅ ព្រោះសិក្ខិយវត្តសម្រាប់បព្វជិតនេះ តែលប់បាត់បន្តិចម្តង ៗ ទៅហើយ អាបត្តិតូចតាចមិនសូវអើពើប៉ុន្មានទេ ព្រោះអាងថាសម្តែងទៅគង់រួចចាកទោស ។ នេះហើយ ឬ ការបំបែកក្នុងពាក់កណ្តាលសាសនា? ។

សភាពនៃជនទូទៅក៏សុទ្ធតែមានជីវភាពរស់នៅអាស្រ័យ ជនម្នាក់ជាចៅហ្វាយខ្លួន ដែលជានាយសហគ្រាសធំ ៗ ។ ឧទាហរណ៍ដូចជានៅសហរដ្ឋអាមេរិក នាយសហគ្រាសមួយរូបដែលចាត់ថា ជាមហាសេដ្ឋីមួយបានសុទ្ធតែមានកម្មករ រាប់ដល់ចំនួនលាននាក់ ៗ នៅប្រទេសណាក៏ដោយគេសំគាល់ឃើញសភាពនៃការរស់នៅបែបនេះនេះស្ទើរគ្រប់តំបន់ ដែលពាក្យលោកជនពោលថា ជាបរិវាររបស់ពួកមូលធន ។

ដរាបណាតែពួកមូលធនមិនទាន់រលត់ចាកពិភពលោកទេ ដរាបនោះប្រជាជនពិភពលោកនៅតែថោកទាបនឹងខ្សត់ខ្សោយជានិច្ច

ដើម្បីរកសេចក្តីពិត ក្នុងពាក់កណ្តាលសាសនា ខ្ញុំសូមអំពាវនាវដល់ពុទ្ធជនទាំងឡាយ ដែលយើងបានធ្វើមធ្វើពិធីរំលឹកពុទ្ធសករាជ២៥០០ រួមគ្នានោះ សូមឲ្យតាំងចិត្តគោរពឲ្យមាំតាមពុទ្ធដីកា ដែលមានចារិកក្នុងផ្ទៃនៃបិដកទាំងបី៖ សូមព្រះសង្ឃប្រុងប្រយ័ត្នវិន័យសិក្ខាឲ្យមែនទែន ។

លោកជនក៏គួរលះបង់ការជិះជាន់គ្នា និងការបង់ចាញ់ឈ្នះគ្នាតទៅអនាគត

ជយោ! ពុទ្ធសករាជ២៥០០



# ពុទ្ធទស្សនៈ (ត)

២– ការបរិភោគកាម ក៏ទ្រង់បាន ជ្រាបច្បាស់ហើយថា ; ជាសឹកសត្រូវ ដល់ការស្ងប់រម្ងាប់, ព្រោះថា: កាល បើរបស់ណាធ្វើឲ្យកើតសេចក្ដីសប្បាយ រីករាយខ្លាំង របស់នោះទុកដូចជាអន្ទាក់ ចងរួបរឹតចិត្តទុក មិនឲ្យបំរើនសមាធិ បាន, កាលទ្រង់ត្រាស់ឃើញហេតុ ទាំងពីរយ៉ាងនេះហើយ ទើបទ្រង់បដិ-សេធគំនិតនេះចេញ

៣– ស្ដេចទ្រង់ប្រព្រឹត្តទៅក្នុង ផ្លូវកណ្ដាល, ផ្លូវកណ្ដាលនោះជាផ្លូវនាំ ព្រះអង្គឲ្យទៅកាន់ការ ត្រាស់ដឹងដល់ទី បំផុត, នេះគួរបាត់ទុកថា: កាល ទ្រង់ជួបប្រទះផ្លូវ កណ្ដាលនោះហើយ

ជាជាន់ទី១ គឺជាដំណើរដែលនាំព្រះពុទ្ធជាម្ចាស់ឡើងទៅកាន់ការត្រាស់ដឹងជាជាន់ទីបំផុត ។

កាលដែលព្រះពុទ្ធជាម្ចាស់ទ្រង់បំពេញទុក្ករកិរិយានោះ លទ្ធផលដែលត្រូវបានគឺទ្រង់មានឧកាសបានស្ងប់ពិតជាងមុន ព្រោះធ្វើឲ្យព្រះអង្គនៅតាមទំនេងព្រះអង្គ ។ កាលទ្រង់កំពុងធ្វើទុក្ករកិរិយា មានអ្នកបួស៥រូបហៅថា "បញ្ចវគ្គិយភិក្ខុ" តាមទៅប្រណិប័តន៍បំរើព្រះអង្គ តាំងពីកាលចេញទៅបព្វជ្ជា ។ អ្នកបួសទាំង៥រូបនោះគឺៈ "កោណ្ឌញ្ញ១, វប្ប១, ភទ្ទិយ១, មហានាម១, អស្សជិ១, បានចេញបួសថ្វាយខ្លួនជាសិស្សបដ្ឋាកៈ; ព្រោះលោកបានជ្រាបពាក្យទំនាយមកថា: បើព្រះអង្គស្តេចចេញបព្វជ្ជា នឹងបានត្រាស់ដឹងនូវធម៌ខ្ពស់បំផុត, បើបានត្រាស់ដឹងហើយ ទ្រង់នឹងប្រៀនប្រដៅខ្លួនឲ្យត្រាស់ដឹងផង; លុះឃើញព្រះអង្គឯលះបង់ការតមាន ព្រះអង្គហើយត្រឡប់ជាសោយអាហារឡើងវិញ ពួកបញ្ចវគ្គិយក៏សំគាល់ថា: ព្រះអង្គអស់សេចក្ដីព្យាយាមនឹងបំពេញតបៈតទៅទៀតហើយ ទើបបបួលគ្នាចៀសចេញអំពីព្រះអង្គទៅ នាំគ្នាទៅនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី ។ ចំណែកព្រះពុទ្ធជាម្ចាស់ទ្រង់គង់ប្រថាប់នៅក្នុងដំបន់ឧរុវេលា ទ្រង់បានជួបប្រទះនឹងសេចក្ដីស្ងប់ស្ងាត់យ៉ាងបរិបូណ៌ ជាហេតុធ្វើឲ្យងាយដល់ការបំពេញពិធីរកធម៌ប្រសើរតទៅ ដរាបដល់បានសម្រេចផល នៃការត្រាស់ដឹងនូវធម៌វិសេស ដូច្នេះទើបទ្រង់ពេញព្រះទ័យថា: «ដឹងពិតហើយ» ក្នុងរាត្រីនៃវិសាខបុណ្ណមី ព្រះចន្ទពេញវង់សោយវិសាខនក្ខត្តឫក្ស (គឺថ្ងៃពេញវង់ខែទី៦ តាមចន្ទគតិ) មុនពុទ្ធសក

៤៥ឆ្នាំ ។

រឿងត្រាស់ដឹងរបស់ព្រះពុទ្ធជាម្ចាស់តាមចាស់ទុំធ្លាប់ដំណាលប្រាប់កូនក្មួយនោះថា ជារឿងសំដែងឫទ្ធិបាដិហារិយ៍ ដើម្បីធ្វើឲ្យមនុស្សក្នុងយុគនោះ កើតសេចក្ដីជ្រះថ្លាចំពោះព្រះពុទ្ធជាម្ចាស់, លុះដល់មនុស្សយុគបរមាណូនេះ គេនាំគ្នាយល់ឃើញថាៈ «ជារឿងបោកទាប» ។

ន័យនេះបើតាមពិត សូមពិសោធន៍សាកល្បងមើលឲ្យជាក់ស្ដែងសិន គង់អាចឃើញថាៈ រឿងសំដែងបាដិហារិយ៍ផ្សេងៗ របស់ព្រះពុទ្ធជាម្ចាស់នោះ ព្រះអដ្ឋកថាចារ្យ លោកតែងឡើងសម្រាប់ជាគ្រឿងឧបមា ដូចគ្នានឹងចិត្តកវីតែងរឿងបុរស-ស្ត្រីនោះ អ្នកសរសេរតែងរកមធ្យោបាយ ទាញប្រសាទអ្នកអានឲ្យឃើញថា អស្ចារ្យស្អាតល្អដូច្នោះឯង ៗ កាលបើយើងអានក្នុងកវីនិពន្ធណាមួយ ឃើញសាច់រឿងថា នារីមួយរូបភ្នែកជាផ្កាយ សម្បុរស្បែកជាផ្កាម្លិះ សក់ដូចជាមេឃក្នុងវេលាយប់ កដៃដូចជាប្រមោយដំរី ។ល។ យើងមុខជានឹងមិននឹកជឿថាៈ នាងនារីនោះមានសភាពដូច្នោះពិតៗ ឡើយ, ដូចនេះយើងសន្និដ្ឋានថាៈ អ្នកតែងគ្រាន់តែជាគ្រឿងប្រៀបធៀបក្នុងចំណែកផ្សេងៗ នៃរូបនារីនឹងរបស់នោះៗប៉ុណ្ណោះ, បើចូលចិត្តដូច្នោះហើយ គង់មិនអាចពោលតិះដៀលថា កវីនោះពោលអ្វីតែងអ្វី សុទ្ធតែជារបស់មិនគួរជឿបានឡើយ ក្នុងរឿងបាដិហារិយ៍របស់ព្រះពុទ្ធជាម្ចាស់នៃយើងក៏គួរសន្និដ្ឋានទុកក្នុងចិត្តដូចនោះដែរថាៈ ព្រះបោរាណាចារ្យ បានរចនាសេចក្ដីនោះឡើង ជាគ្រឿងឧបមាដូចគ្នានឹងចិត្តកវីដូច្នោះឯងៗ ដូចក្នុងរឿងមុនដែលព្រះអង្គបានត្រាស់ដឹងថ្មីៗ នោះ

មានពេលដល់ស្តេចមារថា៖ ក្រែងព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងធម៌ដ៏វិសេសហើយ នឹងកន្លងផុតអំណាចរបស់ខ្លួន ទើបលើកទ័ពមក កាន់ដំបងទរុំវេលា បង្គាប់ពួកពលចូលផ្ចាញ់មានដំរីគិរីមេ-ខល ដែលខ្លួនជិះចូលទៅកាន់ព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គកំពុងប្រថាប់នៅក្រោមដើមពោធិ, ពេលនោះព្រះអង្គក៏ទ្រង់ឈ្នះមារព្រមទាំងបរិវារទាំង-ពួងដោយធម្មវិធី គឺបារមីទាំង ១០ ដែលទ្រង់បានបំពេញមក ៗ រឿងនេះបើពិសោធន៍មើល ក៏អាចឃើញថា៖ ស្តេចមារនោះ លោកមិនមានបំណងពោលដល់យក្សឯណានិមួយ ដែលជាយក្សមានរូបពិតៗនោះឡើយ គឺលោកពោលសំដៅយក កិលេសកាមប្រៀបដោយស្តេចមារ នឹងកិលេសដទៃៗជាសេនារបស់មារ ៗ កិលេសនោះ កើតឡើងក្នុងព្រះហឫទ័យរបស់ព្រះពុទ្ធជាម្ចាស់ ធ្វើឲ្យទ្រង់កង្វល់រលឹកដល់សេចក្តីសោយសុខសម្បត្តិក្នុងអតីតកាល ទុកដូចជាស្តេចមារនឹងសេនារបស់មារដែលមកផ្ចាញ់ ៗ វិធីដែលទ្រង់បង្ខំព្រះហឫទ័យមិនឲ្យនឹក ទៅដល់កិលេសនោះៗ ក៏គឺទ្រង់រំលឹកដល់ព្រះបារមីទាំង ១០ ដែលទ្រង់បំពេញមកហើយ ធ្វើឲ្យព្រះហឫទ័យនឹងហ្ន មិនរំភើប ហាមឃាត់ព្រះហឫទ័យមិនឲ្យកង្វល់អាឡោះអាល័យ គិតដល់ការណ៍ខាងក្រោយជាដាច់ខាត យ៉ាងនេះទើបហៅថា ព្រះអង្គទ្រង់ផ្ចាយព្រះបារមីទាំង ១០ តស៊ូនឹងមារ ៗ

(នៅមានត)

# ដំណឹងសាសនា

ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

## ការបួស

ការបួសជាករណីយកិច្ចប្រចាំជីវិតរបស់ពុទ្ធសាសនិកជនជាតិខ្មែរ ជាប់មកយូរយារណាស់ហើយ ព្រោះការបួសជាការផ្លាស់ចិត្ត ដែលធ្លាប់រាយមាយសាន់វណ្ឌប្រឡូកប្រឡល់នៅក្នុងរឿងលោក ឲ្យមកតាំងនៅក្នុងអាការស្ងប់ស្ងៀម ។

ការបួស បើបួសជាសាមណេរ ហៅថា "បព្វជ្ជា" បើបួសជាភិក្ខុ ហៅថា "ឧបសម្បទា" ។ ប្រពៃណីរបស់ខ្មែរ កាលកុលបុត្រមានអាយុ ២០ ឆ្នាំបរិបូណ៌ ដែលជាអាយុនៅក្នុងវយៈកាលដែលពប់ថា អ្នកមានចិត្តធ្ងន់ធ្ង អាចអត់ធន់បំពោះសេចក្ដីស្រេកឃ្លានបាន ក៏ត្រៀមខ្លួននឹងបួស ប្រុងប្រៀបគ្រឿងអដ្ឋបរិក្ខារ គឺចីពរ ស្បង់ សង្ឃាដិ បាត្រ កាំបិតមួល វត្តពន្ធ បរង្កះ ធមក្រក (តម្រងទឹក) ត្រៀមអដ្ឋបរិក្ខារទាំងនេះ ទុកឲ្យគ្រប់មុនបួស ប្រមាណជា ១៥ ថ្ងៃឬ១ខែ ។ អ្នកគ្រប់គ្រងគឺមាតាបិតាជាដើម ត្រូវនាំកូនចៅដែលប្រុងបួស ទៅផ្ញើទុកនៅនឹងលោកគ្រូចៅអធិការវត្ត ដើម្បីហាត់រៀនវិធីបួសក្នុងកាលដ៏សមគួរ ។

ការទៅហាត់វិធីបួស ហៅថា "នាគ" កាលបើបានជានាគហើយ

អ្នកគ្រប់គ្រង ឬអ្នកទំនុកបម្រុង ត្រូវហាមឃាត់នាគនោះ កុំឲ្យដើរលេងផ្តេសផ្តាស ក្រែងមានរឿងហេតុកើតឡើង ជាការណ៍បណ្តាលនាំឲ្យនាគនោះខានបួស ។

ពាក្យថា « នាគ » ប្រែថា «អ្នកប្រសើរ, អ្នកមិនធ្វើអំពើបាប » បានសេចក្តីថា អ្នកបម្រុងនឹងបួសជាមនុស្សប្រសើរ ជាមនុស្សមិនធ្វើអំពើអាក្រក់ ។

ការបួស ត្រូវបួសក្នុងរោងឧបោសថ (១) ព្រោះរោងឧបោសថនៅក្នុងខេត្រសីមា ។ ការបួសជាសង្ឃកម្មមួយត្រូវធ្វើក្នុងខេត្រសីមា ។

ពាក្យថា « សីមា » សំគាល់យកខេត្រសម្រាប់កំណត់ឲ្យជាទីធ្វើការរបស់សង្ឃ ។ វត្តខ្លះមានសីមានៅជុំវិញរោងឧបោសថ វត្តខ្លះមានសីមានៅប្របកំពែងវត្តជុំវិញ ដំណើរទាំងនេះ ដើម្បីឲ្យដឹងថាខេត្ររបស់សង្ឃ សម្រាប់ធ្វើសង្ឃកម្ម មានការបួសជាដើម ។.

ការបួស សម្រេចនៅលើសង្ឃ បើវត្តមិនសម្បូណ៌លោកសង្ឃ ត្រូវមានយ៉ាងតិចត្រឹម ៥ រូប បើវត្តសម្បូណ៌លោកសង្ឃយ៉ាងតិចត្រឹម១០រូបហើយ មានព្រះថេរៈ ១ រូបជាព្រះឧបជ្ឈាយ៍ គឺជាប្រធានក្នុងការបំបួស ទាំងជាអ្នកត្រួតត្រាមើលទោសតូចធំ របស់អ្នកបួស ត្រូវសន្មតភិក្ខុ ១ រូប ឬ ២ រូបឲ្យជាអ្នកសាកសួរនូវអន្តរាយិកធម៌ របស់អ្នកបួសចំពោះជុំនុំសង្ឃថា អ្នកមានរោគឃ្លង់ បូស ស្រែង ហិត ឆ្កួតជ្រូកជាដើមដែរឬ កាលបើសួរអន្តរាយិកធម៌ស្រេចហើយ ត្រូវសូត្រញត្តិក្នុងលំដាប់តទៅ ។ លុះចប់ញត្តិហើយ ទើបព្រះឧបជ្ឈាយ៍ ប្រាប់អនុសាសនវិធី

១— ចំពោះបួសជាភិក្ខុ ។

គឺប្រៀនប្រដៅអ្នកបួសថ្មី ឲ្យដឹងនូវកិច្ច ខាងដើមមុនដំបូងបង្អស់ គឺនិស្ស័យគ្រឿងអាស្រ័យរបស់បព្វជិតមាន ៤ យ៉ាង :

១–. ត្រាច់ទៅបិណ្ឌបាត

២–. ស្លៀកដណ្តប់សំពត់បង្សុកូល

៣–. នៅជិតគល់ឈើ

៤–. ឆាន់ថ្នាំដែលត្រាំដោយទឹកនោមស្អុយ(១) ។

និស្ស័យទាំង ៤ យ៉ាងនេះ ព្រះសម្ពុទ្ធបាន អនុញ្ញាត ក្នុង សម័យ ដែលស្រុកទេសមិនសម្បូណ៌ កំពុងក្រីក្រ ដុនដាប ឥឡូវសម័យនេះស្រុកទេសបាន ចំរើន រុង រឿង សម្បូណ៌ ដោយគ្រឿងប្រើប្រាស់ផ្សេងៗ ភាពនៃភិក្ខុក៏ប្រែប្រួលប្រព្រឹត្តទៅតាមសេចក្តីចំរើនរបស់ស្រុកទេសដែរ ។ ត្រង់បទថា ឲ្យភិក្ខុស្វែងរកសំពត់បង្សុកូលដោយទីកន្លែង ដែលគេចោលលើគំនរអាចម៍ដីឬតាមទីប៉ាឆាមកធ្វើជាសំពត់សម្រាប់ស្លៀកដណ្តប់ សម័យនេះ សំពត់មានសាច់ល្អៗក៏ច្រើន ទាំងទាយកអ្នកមានសទ្ធាជ្រះថ្លាក៏មានច្រើនដែរ ទើបអនុញ្ញាតឲ្យភិក្ខុប្រើប្រាស់សំពត់មានសាច់ល្អៗ បាន ។ ត្រង់បទថា ឲ្យភិក្ខុនៅជិតគល់ឈើ, ឥឡូវសម័យនេះវត្តអារាមមានច្រើនកុះករ ទើបអនុញ្ញាតឲ្យភិក្ខុនៅតាមវត្តអារាមបាន ។ ត្រង់បទថា ឲ្យភិក្ខុឆាន់ថ្នាំដែលត្រាំដោយ

---

១– ត្រង់បទថា បូតិមុត្តៈ ប្រែថាទឹកនោមស្អុយ ពុំប្រាកដជាទឹកនោមមនុស្ស ឬទឹកនោមគោ តែបើតាមសង្កេតមើលទៅ ឃើញថាទឹកនោមមនុស្សនោះពុំសមសោះ ព្រោះមានបទបញ្ញត្តថា ភិក្ខុឆាន់សាច់-ទឹកដោះសក់និងរោមមនុស្សមិនបានទេ ប្រហែលជាទឹកនោមមនុស្សក៏មិនបានដែរ បើទឹកនោមគោទើបគួរ ព្រោះក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈ ទំព័រលេខ ៤២៥ កែបទ បូតិមុត្តំ ថា យំ កិញ្ចិ គោមុត្តំ ប្រែថា ទឹកនោមគោណាមួយ ។

ទឹកនោមស្អុយ សម្រាប់បំបាត់រោគផ្សេងៗ សម័យនេះ មានមន្ទីរពេទ្យជាច្រើន សម្បូណ៌ដោយថ្នាំកែរោគ ហើយ ទើបអនុញ្ញាតឲ្យភិក្ខុប្រើថ្នាំតាមក្បួនពេទ្យបាន ។

លំដាប់តទៅ ព្រះឧបជ្ឈាយ៍ គប្បីប្រាប់អករណីយកិច្ច គឺកិច្ចដែលអ្នកបួសមិនត្រូវធ្វើមាន ៤ យ៉ាង

១–. មិនត្រូវសេពមេថុន

២–. មិនត្រូវលួចលាក់របស់គេ

៣–. មិនត្រូវសម្លាប់សត្វ

៤–. មិនត្រូវពោលអួតគុណវិសេស ដែលមិនមានក្នុងខ្លួន ។

កាលព្រះឧបជ្ឈាយ៍ បានប្រាប់និស្ស័យ ៤ នឹងអករណីយកិច្ច ៤ ដូចពោលមកដោយសង្ខេបនេះ ឈ្មោះថាចប់អនុសាសនវិធីត្រឹមប៉ុណ្ណេះ ។ អ្នកបួសថ្មីក៏តាំងខ្លួន តម្រង់ភាពជាភិក្ខុក្នុងព្រះពុទ្ធសាសនា ហៅអ្នកបួសនោះថា "ភិក្ខុ" ព្រោះជាអ្នកសូមគឺជាអ្នកទទួលទេយ្យទានអំពីទាយក; ហៅថា "បព្វជិត" ព្រោះជាអ្នកវៀរចាកអំពើមានទោសគ្រប់យ៉ាង; ហៅថា "សមណៈ" ព្រោះជាអ្នកស្ងប់រម្ងាប់សេចក្តីអាក្រក់ ; អ្នកដែលបានបួសហើយនេះ ឈ្មោះថាជាអ្នកជួយតម្រង់ព្រះពុទ្ធសាសនា ឲ្យបានគង់ ឲ្យបានរុងរឿងជាស្ថាពរដរាបមកដល់សម័យបច្ចុប្បន្ននេះឯង ។

(នៅមានត)

## ព្រះពុទ្ធសាសនាប្រទេសកម្ពុជាកំពុងដើរទៅកាន់សេចក្តីចំរើន

## ជនជាតិបរទេសទីពីរបានចូលមកសូមផ្នួសនៅកម្ពុជរដ្ឋ

កាលពីពេលមុនមានជនជាតិបារាំងម្នាក់បានចូលមកសូមផ្នួសនៅវត្តខណ្ណា-

លោម ដូចអស់លោកអ្នកបានជ្រាបហើយ ។

បន្ទាប់មកមានកុលបុត្រជាតិអូស្ត្រាលីម្នាក់ឈ្មោះ ស៊ីដនេយ ហង់រីហ៊ីល្ល (Sydney Henry Hill) អាយុ ២៦ឆ្នាំ ក្រោយដែលបានទៅកាន់ប្រទេសភូមានិងថៃបានសង្កេតឃើញព្រះពុទ្ធសាសនានៅប្រទេសអស់នោះ មានសេចក្ដីពេញចិត្តហើយក៏មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា, នៅពេលសន្និសីទនៃពុទ្ធិកសមាគមពិភពលោកលើកទី ៣ នាក្រុងរង្គូនប្រទេសភូមា គ.ស ១៩៥៤ កុលបុត្រនេះបានជួបនឹងព្រះសង្ឃជាតិខ្មែរ មានព្រះតេជព្រះគុណព្រះពោធិវង្សជាប្រធាន បានសង្កេតឃើញសណ្ដាប់ធ្នាប់ដ៏ស្រគត់ស្រគំនៃព្រះសង្ឃទាំងនោះ ហើយថែមទាំងបានឮពត៌មានពុទ្ធសាសនានៅកម្ពុជរដ្ឋ ពីលោកម៉ោរីស ជាតិអូស្ត្រាលីញើ ការនៅពុទ្ធសាសនសភាប្រទេសភូមាដែលបានសង្កេតឃើញនៅពេលដែលគាត់បានមកកាន់ប្រទេសខ្មែរ ក៏មានសេចក្ដីជ្រះថ្លាយ៉ាងក្រៃលែងចំពោះព្រះសង្ឃខ្មែរ ទើបសូមចូលមកកាន់ប្រទេសខ្មែរ សូមបព្វជ្ជាជាសាមណេរក្នុងព្រះវិហារវត្តឧណ្ណាលោម នៅថ្ងៃទី ២៨ មករា គ.ស.១៩៥៦ វេលាម៉ោង ១៧ ។

ពុទ្ធិកសមាគមកម្ពុជរដ្ឋដែលមានគោលបំណងខាងការផ្សាយព្រះពុទ្ធសាសនានិងការចងមេត្រីភាពជាមួយនឹងពុទ្ធិកសមាគមប្រទេសអូស្ត្រាលី ព្រមទាំងចង់ឲ្យសាមណេរនេះជួយបង្ហាត់បង្រៀនភាសាអង់គ្លេស ជាជីវភាសា ដែលគ្រប់ ៗ ប្រទេសគេនិយមរាប់អានសព្វថ្ងៃដល់ភិក្ខុសង្ឃជាតិខ្មែរផងទៅ ដើម្បីជាការស្រួលដល់ការផ្សាយព្រះពុទ្ធសាសនាទៅក្នុងសាកល

លោកផងនោះក៏បានរ៉ាប់រងឧបត្ថម្ភទំនុកបំរុងចាប់តាំងពីពេលដើមមកដល់រហូតដល់ពេលបួស ។

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណមហានិកាយ ជាព្រះឧបជ្ឈាយ៍ ដោយមានព្រះពោធិវង្ស នឹងព្រះរាជាគណៈឋានានុក្រមជាច្រើនអង្គគង់អមនៅពេលនោះផងៗ ចំណែកខាងឧបាសកមានឯកឧត្តម សម-ញាណ ប្រធានពុទ្ធិកសមាគម, លោករ៉ាយ-ប៊ុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យព្រមទាំងពុទ្ធបរិស័ទជាច្រើន , មានអង្គទូតប្រទេសអង់គ្លេស,អាមេរិក, អូស្ត្រាលី, ថៃ, ជប៉ុន, ចិននឹងជាតិបារាំង បានអញ្ជើញទៅជាភ្ញៀវកិត្តិយសក្នុងពិធីនេះដែរ ។

សម្តេចបានប្រទាននាមបញ្ញត្តិថា ធម្មរតនៈ, នៅពេលបព្វជ្ជាស្រេច, សាមណេរនេះបានថ្លែងអំណរគុណចំពោះភ្ញៀវទាំងអស់ ។

ឯកឧត្តម សម-ញាណ បានថ្លែងសុន្ទរកថាមួយជាភាសាខ្មែរ រៀបរាប់អំពីពិធីបុណ្យបំបួសលោក សាមណេរនោះ បន្ទាប់មកលោកប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ ថ្លែងសុន្ទរកថាជាភាសាបារាំង ។

សាមណេរនេះ ស្ថិតនៅក្នុងការបង្ហាត់បង្រៀនផ្ទាល់ នៃព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

នេះជាគោលសំខាន់មួយ គួរចារឹកទុកក្នុងប្រវត្តិសាស្ត្រព្រះពុទ្ធសាសនាកម្ពុជរដ្ឋ ។

ឯសុន្ទរកថារបស់ ឯកឧត្តមប្រធានពុទ្ធិកសមាគម យើងនឹងចុះផ្សាយជូនក្នុងលេខក្រោយ ។

ប៊ុណ្ណ - សុម្ភាជ

×××

ព្រះមហាថេរកុល-ទេស ត្រូវតែងតាំងជាព្រះពុទ្ធចារ្យស្ដីទី សង្ឃនាយកគណៈធម្មយុត្តិ ជំនួសសម្ដេចព្រះសុធម្មាធិបតី ដែលទើបនឹងអនិច្ចធម្មថ្មីៗនេះ សមាគមសូមបួងសួងដល់គុណព្រះរតនត្រ័យ សូមឲ្យសម្ដេចគង់នៅជាសុខ ប្រាសចាកឧបសគ្គគ្រប់យ៉ាងក្នុងការគ្រប់គ្រងព្រះសង្ឃរៀបចំសាសនាឲ្យបានចំរើនតទៅអនាគត ។

×××

ទើបនឹងបានទទួលដំណឹងថ្មីមួយទៀតថា នៅកណ្ដាលទីក្រុងទេព (ប្រទេសថៃ) គេបានរកឃើញព្រះពុទ្ធរូបមួយព្រះអង្គជាវិការៈនៃមាសសុទ្ធ មានទម្ងន់ប្រហែលជា ៥ តោន ។

តាមដំណឹងក្រៅផ្លូវការថា នៅទីអារាមចាស់មួយយូរមកហើយ មានព្រះពុទ្ធរូបថ្មមួយអង្គ តាមបក្ខុអ្នកពិនិត្យព្រះពុទ្ធរូបនេះរដ្ឋាភិបាលថៃ បានយកទៅប្រគេនព្រះសង្ឃជាចៅអាវាស ក្នុងអារាមនៃរាជធានីថៃ ព្រះមហាថេរក៏លោកពុំសូវយកចិត្តទុកដាក់ ចំពោះព្រះពុទ្ធរូបនោះប៉ុន្មាន ក៏បណ្ដោយឲ្យនៅក្នុងទីវាលធម្មតា លុះកន្លងពេលជាយូរមក ព្រះមហាថេរជាចៅអាវាសក៏នឹកក្នុកដល់ការសង់ប្ហាមួយ សម្រាប់ដម្កល់ព្រះពុទ្ធរូបអង្គនោះ លុះទីសំណាក់សង់រួចហើយ ព្រះមហាថេរក៏ចាត់ចែងការ ដើម្បីនិមន្តព្រះពុទ្ធរូបទៅកាន់ទីសំណាក់ ការចាប់សែងព្រះរូបជាលើកដំបូង ក៏បណ្ដាលឲ្យរបេះស៊ីម៉ង់ដែលស្រោបព្រះហស្ត ហើយលោកក៏បានវត្ថុមួយ មានពណ៌ខ្មៅនៅខាងក្នុង លោកបានយកវត្ថុនេះមកកោសមើល ក៏ដឹងច្បាស់ថាជាមាសសុទ្ធ បន្ទាប់មកក៏ចាប់ផ្ដើមបំបែកស៊ីម៉ង់ ដែលប៉ុកពីក្រៅព្រះពុទ្ធរូបនោះចេញ ។ គេបានឃើញខ្មៅនៅគ្រប់កន្លែង ដែលអាច

ដោះចេញបាន គ្រប់អវយវៈ ព្រះរូបទាំងអស់ ។

សព្វថ្ងៃនេះ រដ្ឋាភិបាលថៃបាន ចាត់ចែងឲ្យកងរក្សាជាតិ មករក្សាដោយការខ្ជាប់ខ្ជួន ដើម្បីបៀសវាងការរំលោភ ដែលនាំឲ្យផ្ទុយពីច្បាប់ព្រះពុទ្ធសាសនា ។

---

ការចូល កាន់មរណៈ

សញ្ញា ចំពោះ



សម្តេចព្រះមហា សុធម្មាធិបតី

សង្ឃនាយក គណៈធម្មយុត្តិវត្តបទុមវតី

ក្រុងភ្នំពេញ

នៅថ្ងៃទី ខែមករា សម្តេចជាម្ចាស់ ត្រូវជរារោគដ៏មានកម្លាំងចូលមកបៀតបៀនព្រះរូបកាយព្រះអង្គ ហើយបណ្តាលឲ្យផ្តាច់ព្រះជន្ម នៅចំពោះមុខសិស្សានុសិស្សទាំងគ្រហស្ថនិងបព្វជិត ដោយមិនមានការគោតញាញើតអ្វីបន្តិចឡើយ

នៅលើមហាកុដិផ្ទាល់ព្រះអង្គ ។

សមាគមមិត្តពុទ្ធិកវិទ្យាល័យ, និមិត្តតែឮដំណឹងនេះភ្លាម ក៏មានការស្រពោននិងស្ងប់ស្ងៀមយ៉ាងខ្លាំង ដោយស្តាយស្រណោះសម្តេចស្មើនឹងជីវិតផ្ទាល់ខ្លួន, ព្រោះសម្តេចជាអង្គអគ្គប្រាជ្ញមួយរូបក្នុងមណ្ឌលពុទ្ធសាសនាកម្ពុជរដ្ឋ ដែលបានបំភ្លឺដឹកនាំពុទ្ធជនកម្ពុជរដ្ឋ ឲ្យដៀស្គាល់សភាពគុណ-ទោស និងសាមគ្គីធម៌រវាងពុទ្ធជនមេត្តា, ហេតុនោះសេចក្តីទុក្ខសោកសៅទាំងឡាយដែលកើតឡើងដោយកម្លាំងអកុសលចិត្តនៃមច្ចុរាជ យើងខ្ញុំសូមឲ្យសេចក្តីទុក្ខនោះក្លាយទៅជាសេចក្តីទុក្ខមេត្តា ដោយទឹកចិត្តដ៏បរិសុទ្ធចំពោះសពសម្តេច ហើយសូមកុសលពលីទាំងឡាយដែលកើតឡើងដោយកម្លាំងសមាគមតាំងពីដើមរៀងដរាប ទៅជួយឧបត្ថម្ភវិញ្ញាណក្ខន្ធសម្តេច សូមឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាងក្នុងភពថ្មី និងទីបំផុតសូមឲ្យបានមកជួបមុខយើងខ្ញុំរាល់គ្នាវិញដើម្បីត្រងត្រាប់ឱវាទព្រះអង្គតទៅទៀត ។

# សេចក្តីកត់ហេតុមហាសន្និបាត

ថ្ងៃអាទិត្យទីប្រាំបី ខែមករា ឆ្នាំមួយពាន់ប្រាំបួនរយហាសិបប្រាំមួយ (៨, ១, ៥៦) ។

ក្រុមសមាជិកនៃសមាគមមិត្តសាលាបាលី ទាំងបព្វជិតនិងគ្រហស្ថ បាននិមន្តនិងអញ្ជើញមកកាន់ទីមហាសន្និបាតនៅសាលាបាលីរង វត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ ។

ផ្នែកខាងព្រះសង្ឃ មានចំនួន ១ រយអង្គ មានសម្តេចព្រះធម្មលិខិតឧត្តម ប្រឹក្សាគណៈមហានិកាយវត្តលង្កា និងព្រះគ្រូអាយកស្សបអ៊ូច ជាតំណាង

សម្តេចសង្ឃនាយកគណៈធម្មយុត្តិជាដើម ។ ផ្នែកខាងគ្រហស្ថមាន ឯ.ឧ. សម ញាណ, ឯ.ឧ. ក៉យ-លុត, ឯ.ឧ. អ៊ុក-ជុប, លោកក៉យ-ប៊ុក អធិបតីសមាគមនេះ និងឥស្សរជនឯទៀត ព្រមទាំងអស់លោកស្រី-អ្នកស្រី សមាជិក-សមាជិកាចំនួន ៤៩ នាក់ ។

លុះដល់ពេលម៉ោង ១៦ នឹង ២៥ នាទី (ម៉ោង ៤ នឹង ២៥ នាទីរសៀល) ហើយលោកអធិបតីបើកសម័យផ្តើមមហាសន្និបាត បានថ្លែងសុន្ទរកថា រៀបរាប់អំពីសកម្មភាពនៃសមាគមនៅក្នុងឆ្នាំ ១៩៥៥ ដូចមានក្នុងសេចក្តីសុន្ទរកថាស្រាប់ ។ លុះចប់ហើយសមាជិកបានទះដៃជាសញ្ញាទទួលអំណរយ៉ាងក្រៃលែង ។

បន្ទាប់ពីនោះមកលោក ម៉ៅ-ម៉ី ជាអគ្គហេរញ្ញិក បានថ្លែងការណ៍រៀបរាប់អំពីប្រាក់ចំណូលចំណាយ ហើយសព្វគ្រប់ដូចមានសេចក្តីថ្លែងការណ៍នោះស្រាប់ ។

តមកទៀតលោកផេង-ជ្រីវ បានថ្លែងសុំយោបល់កែប្រែលក្ខន្តិកៈ ក្នុងមាត្រាខ្លះ ដូចមានរៀបរាប់តទៅនេះ

១– មាត្រាទី ៧ ចំពូកពីរអំពីសមាជិកនៃសមាគមនេះ ៧ ប្រភេទត្រង់ប្រភេទទី៣ទី៤-៥- គឺជនកសមាជិកឧបការីសមាជិក, ទាយកសមាជិកទាំង៣ប្រភេទនេះកាលបើបានបង់ប្រាក់គ្រប់ចំនួនតាមឋានៈប្រភេទនោះ តែម្តងហើយលែងមានការបង់ប្រាក់ប្រចាំខែទៀតឡើយ, ឥឡូវសុំកែថា ទោះបីបានបង់ប្រាក់គ្រប់ចំនួនតាមឋានៈក្នុងប្រភេទនិមួយៗ ហើយក៏សូមឲ្យបង់ប្រាក់ប្រចាំខែក្នុង១ខែ១០រៀលតទៅ ។

មហាសន្និបាត ក៏បានមូលមតិគ្នាជាឯកច្ឆន្ទតាមពាក្យកែប្រែនោះ ។

២– អំពីកម្មកសមាជិកពីឆ្នាំ

មុនៗមកសមាជិកទាំងអស់បង់ក្នុងមួយខែ ៥៛០០ ឥឡូវសុំកែប្រែទៅជា ១០៛០០ ក្នុងមួយខែវិញ ។ មហាសន្និបាតក៏បានសម្រេចយល់ព្រមហើយ មូលមតិគ្នាជាឯកច្ឆន្ទ ។

៣– អំពីរឿងប្រាក់ក្នុងហិបសមាគម កាលបើលើសពីមួយហ្មឺនរៀល (១០.០០០៛០០) ឡើងទៅត្រូវយកទៅដាក់ក្នុងធនាគារជាតិ សុំកែថាបើកាលណាលើសពីមួយហ្មឺនរៀលឡើងទៅ (១០.០០០៛០០) ឡើងទៅទោះបីយកទៅដាក់ក្នុងធនាគារជាតិឬក្នុងសមាគម ឬក្នុងអង្គការណាក៏ដោយ ឲ្យតែមានការធានាដោយត្រឹមត្រូវ ដើម្បីនឹងយកកម្រៃឲ្យបានចំរើនឡើងទៅទៀតដល់សមាគមយើង ។ រឿងនេះក្រុមមហាសន្និបាត បានដេញដោលគ្នាដោយម៉ត់ចត់អស់កាលជាយូរ ហើយពុំបានសម្រេចយល់ព្រមយ៉ាងណាឡើយ ទើបលើក ខទី ៤ មកពិភាក្សាតទៅទៀត ។

(នៅមានត)

## និទានព្រះសុន្ទរសមុទ្រត្នោរ (តនឹងបប់)

១៩– បីស្រា !(១) ទៅសា ! ពោលមិនចំ
ហាក់បែបបន្ទំពាក្យបោរី
និយាយចេញទៅសុទ្ធពាក្យថ្មី
ព្រោះប្រុសពីរ-បីដើរតាមក្រោយ ។

២០– ពត់ខ្លួនទន្ទេងលេងក្បូរក្បាច់
រាំរែកកែកាច់ស្រែកជន្ហោយ
ដង្ហំផ្សំភ្លេងលេងហាត់ដោយ
បញ្ចើតតាមក្រោយបោយដៃហៅ ។

២១– សុះស្មាពង់ខ្លួតចាប់តន្ត្រីយ

(១) ពាក្យមាយាស្រីអ្នកក្រុង: តាមច្បាប់ស្រីត្រា ទៅវិញ្ញូរ ។

ឃឹមស្រឡៃប៉ុដេញដំដៅ
ស្រះនេះស្រះគោចខ្លោចផ្ការក្តៅ
ខ្សឹតខ្សៀវខ្សឹកខ្សួលរមួលប្រាណ ។
២២- យាសយាងកាប់ពងនាងល្វតល្វន់
បង់ប៉ោយព័ទ្ធព័ទ្ធផាន់ដែនដាន
មុខមាត់ប្រផូរប្រស់កល្យាណ
កុំផាន់ញ៉ែងញ៉ងដើរញ៉ុំញ៉ើ ។
២៣- គុបតែងរត្តពិកូសិត
អលង្ក្រិតទឹកអប់ក្រអូបសើ
បុរសដើរជិតជំប្រហើរ
ដំណើរស្រញន់ដូចអប្ឋរ ។
២៤- រួសរើកកាយខុសទំនង
ទងវង់ខ្ចីកខ្ចក់ក្រៅតម្រា
សើចលេងសប្បាយខូចពង្វា
បែបដូចស្រីផ្កាសន្ហាក្រៃ ។
២៥- សំឡឹងសម្លក់លបគយគន់
ឃើញប្រុសយុវនត្រូវដួងចែ
ញាក់ភ្នែកមិចភ្នែកក្រឡេកវៃ
ផ្ជងសក់ដោយដៃផាសញ្ញា ។

២៦- បើប្រុសក្រឡេកបែរមកចំ
ស្រីមុំនាងញាក់ចង្កេះស្នា
ឲ្យប្រុសលុះលង់កាមតណ្ហា
យាត្រាត្រំប្រួចលួចញាក់តប ។
២៧- បើនាងអគ្គយកណ្ដីស្វាត់
លែងប្រុងប្រយ័ត្នគ្រឿងរបប
របៀបស្រីខ្មែរធ្លាប់ប្រកប
តែជបជល់ដៃបង្ហាញក្លៀក ។
២៨- បញ្ចេញទាក់សដូចចាន
ប្រុសប្រាណសំឡឹងមើលក្លៀកៗ
ស្ទើរទប់ពុំបានយកដៃកៀក
ហៀកហៀរទឹកមាត់ព្រោះឃើញផ្ទៃ ។
២៩- ជួនកាលស្លៀកហូលដរមានជាយ
ធ្លាក់វែងអន្ទាយហួសវិស័យ
ហួសស្រីស្រុកខ្មែរស៊ីវិល័យ
រិចរឹមម៉ែ ៗ ប្រាំថ្ងៃអស់ ។
៣០- កាលខ្វះលាត់ឲ្យឃើញគល់ភ្លៅ
ពងពៅត្រសូលសល្អណាស់
ឲ្យប្រុសនៅជិតខឹងខ្វះ ។

ហៃណាស់តែខានចង់ឃើញពង ៗ

៣១– មែន! ឃើញមែនមិនយូរប៉ុន្មាន

តែស្រីប្រែប្រាណគុហ្យមេនាង

ចេញទតស្ងួនប្យារបំអស់យ៉ាង

ពងកំប៉ាងៗ ដូចស្ទឹកពោធិ៍ ៗ

៣២– ឯអាវសម័យដែលថ្ងៃពាក់

មើលឃើញដាក់ស្ដន់នៅជ្រដោ

ប្រុស ៗ ឃើញច្នោះរកពុំទ្លោ

បើមោហ៍រាំបាំងប្រញាំងរបូត

៣៣– បើនាងគាប់ចៃបុរសណា

នេត្រាផ្អងផ្សៀងដៀងរហូត

ពីដើមដល់ក័ក្ដ្រគ្រប់វគ្គ៉ូត

កន្ទុយនេត្រឆ្កួតជាសញ្ញា ៗ

៣៤– ចិញ្ចើមរាសវង់ពង់យ៉ាងខ្វង់

ដូចកង់អឌ្ឍចន្ទ្រប្រាំកើតណារ

ពព្រើមពព្រាក់ទាំងកេសា

មុខាញ័រញាប់រាប់មិនអស់ ៗ

៣៥– បបូរមាត់ស្រីក្រហមឆ្អៅ

ឯផ្កាល់ចឹមម្យេគ្មានចន្លោះ

ឃើញញាតិទល់ក្រពេបខាកស្ដោះ

ស្រីស្រស់ភ្ញើបុកសក្ដិភូមិ ៗ

៣៦– ដិភ្ហកញ្ញាលៀនញយ ៗ

ប្រុសដើររដយមាត់ហុម ៗ

ដិភ្ហកញ្ញាស្រីក្រមុំ

ប្រមូលប្រុសជុំជាសញ្ញា ៗ

៣៧– ដដុសរលាស់សព្វទុស្សំ

វត្ថុគ្របគ្រប់សព្វមំសា

ម្ដងស្លៀកម្ដងផ្លាស់តាមប្រាថ្នា

ចិត្តានឹកឃើញទាន់សម័យ ៗ

៣៨– សំលៀកបំពាក់រយពាន់គ្រឿង

រុងរឿងរចនាតែទំនៃ

ដួនសដួនលឿងឬវែងខ្លី

មុំស្រីតុបតែងលេងបុកខ្លួន ៗ

៣៩– រំសាយកេសាដោយធូរធ្ងា

ដូចជាអ្នកងាររលាខុសក្បួន

ស្រដៀងបីសាចព្រាយចិនយួន

ចោលក្បួនបុរាណទំនៀមចាស់ ៗ

៤០– បងប្អូរក្បូរក្បាច់រចនា

បុប្ផារយោងពណ៌ច្រើនណាស់
ផ្កានេះផ្កានោះតែផ្ដសផ្ដាស់
ស្អកស្កះពោរពាសពេញកេសា ។
កាលស្ត្រីវេស្យាសំដែងបទ
កំណត់បានសែសិបមាត្រា
ដល់ចប់ទើបហាមាត់ពោលថា
ហៃប្រុសដ៏វាពន្ធកស្រី! ។
ប្អូនសូមអង្វរដោយស្មោះស្ម័គ្រ
ព្រោះយើងពីរនាក់សាប់នៅខ្ចី
បងឯងយុវនប្អូនយុវតី
បានដើរលៀងខ្ចីលាបល័ក្តិស្រស់ ។
ទើបសមនឹងស្បែកជើងទំនើប
រលើងរលើបសព្វទាំងអស់
បណ្ដើរគ្នាលេងដោយកៀនកោះ
ក្រមុំកម្លោះសប្បាយក្រៃ ។
បើយើងអស់បង់ត្រង់តណ្ហា
ដំណាដកស្គមាំងរៃ
សឹមចូលទៅបួសណាប្រុសថ្លៃ
សូមប្រុសប្រឹមប្រិយមេត្តាប្អូន ។

រីឯព្រះសង្ឃអង្គភិក្ខុ
លោកឃើញតែទុក្ខឃើញតែសូន្យ
រូបឥតខ្លឹមសារមិនមែនខ្លួន
ទទឹងមាំមួនគឺត្រៃរត្ន ។
គ្រានោះសម្ដេចព្រះទ្រង់ញាណ
ទ្រង់មានវាចាយ៉ាងគ្រោកដ
ត្រាស់ប្រាប់អានន្ទដោយបែបបទ
កំណត់ជាពាក្យឧបមា ។
ថានែអានន្ទ! ចូរមើលទៅ
លំនៅឥត្ថីវេសិយា
កំពុងតតាំងសង្គ្រាមា
ជាមួយបុត្រាតថាគត ។
អានន្ទបង្គំទូលសួរថា
បពិត្រភគវាចមមកុដ
គបបញ្ញាញាណដ៏មោះមុត
ពិសុទ្ធពិសេសឯកលោកិយ ។
សង្គ្រាមភិក្ខុនឹងវេស្យា
ទ្វេហាវាងណាបរាជ័យ
ភិក្ខុឬមួយវាងនាងស្រី

សូមទានប្រណីស្រាយបញ្ហា? ៗ
ព្រះអង្គត្រាស់ថានែអានន្ទ!
ចិត្តភិក្ខុអន់ខាងតណ្ហា
ព្រោះចុះក្នុងផ្លូវអនត្តា
អសុភសញ្ញាលោកកាន់បាន ៗ
ត្រាស់ស្រេចទើបផ្សាយព្រះរស្មី
ឆព្វណ្ណរង្សីព្រះទ្រង់ញាណ
ទ្ពោះមុខភិក្ខុក្នុងវិមាន
និទានជាបទធម៌ទេសនា ៗ
ភិក្ខុអង្គណាក្នុងលោកិយ
លះក្តីកាមយោគលែងប្រាថ្នា
បោះបង់ចោលផ្ទះកុដិសាលា
កាមទាំងទ្វេហាបារកិលេស ៗ
កាមភពរូបភពអរូបភព
ចិត្តលោកលែងជាប់ផុតវិសេស
ចូលដល់និព្វានមិនមានលេស
ជាឋាននិវេសន៍ផុតទុក្ខភ័យ ៗ
តថាគតហៅភិក្ខុនោះថា
ជាព្រាហ្មណ៍សាសនាព្រះលោកត្រៃ

ប្រាសចាកក្តីហ្មងបង់អាល័យ
ភពត្រៃសង្សារលះចោលបាន ៗ
អវសាននៃព្រះធម៌ទេសនា
បុត្រព្រះសាស្តាលោកក៏មាន
ព្រះទ័យទុនចុះក្នុងផលញាណ
ព្រោះចិត្តតោងស្ថានគឺអរហត្ត ៗ
និទានពីរឿងសុន្ទរ-សមុទ្រ
បុត្រព្រះប្រសើរពន់ពេកក្តាត់
ប្រាំងនឹងស្ត្រីបានអរហត្ត
និទានកាត់ៗយកសេចក្តី ៗ
សូមទោសអ្នកស្រីផងទាំងឡាយ
ក្រមុំមេម៉ាយឬមានប្តី
បើបានអានហើយចូរខន្តី
កុំស្តីនិន្ទាខ្ញុំអ្នកតែង ៗ
ព្រោះខ្ញុំរៀបរៀងតាមតម្រា
បុរាណាចារ្យលោកសំដែង
មានក្នុងគម្ពីរប្រាកដស្តែង
ចារចែងចង់ជាពាក្យបាលី ៗ
ខ្ញុំគ្រាន់តែប្រែបកជាខ្មែរ

តាមប្រាជ្ញបុរាណក្បួនកវី
សង្ខេបប៉ុណ្ណេះទុកដើម្បី
ដល់ញាតិផែនដីខ្មែរយើងអើយ !!! ។

ចាកធម្មបទខុទ្ទកនិកាយ
ម. បូច្រី សិស្សចាស់សាលាបាលីជាន់ខ្ពស់

---

# ប្រវត្តិសង្ខេបនៃនាលន្ទា

លោកអ្នកចាប់ចិត្តខាងប្រវត្តិសាស្ត្រគង់បានប្រទះពាក្យថា "មហាវិទ្យាល័យនាលន្ទា" ការវិវឌ្ឍន៍នៃពុទ្ធសាសនា និងសាសនសិក្សាដែលលូតលាស់ចំរើនឡើងក្នុងសម័យបុរាណបន្ទាប់អំពីពុទ្ធកាល ។

នាលន្ទា គឺជាស្រុកកំណើតជីវភាពរបស់ព្រះអគ្គសាវកទាំងគូនៃព្រះពុទ្ធជាម្ចាស់ គឺព្រះសារីបុត្តត្ថេរនិងព្រះមហាមោគ្គល្លានត្ថេរ (ឧបតិស្សគ្រាមដែលជាភូមិរបស់ព្រះសារីបុត្តឥឡូវនេះគេហៅភូមិសារីចក្រៈ នៅចម្ងាយប្រហែល ១គ.ម.ខាងទិសឦសាននៃ មហាវិទ្យាល័យនាលន្ទាចាស់; គោលិតគ្រាមដែលជាភូមិកំណើត របស់ព្រះមហាមោគ្គល្លាន ឥឡូវនេះ ឈ្មោះភូមិគូលៈ នៅចម្ងាយប្រហែល ២គ.ម. ខាងទិសអគ្នេយ៍នៃមហាវិទ្យាល័យចាស់) ។

នាលន្ទានេះជា មហាវិទ្យាល័យមួយយ៉ាងធំ សម្រាប់ព្រះពុទ្ធសាសនាគ្រាដំបូង ដែលមានឈ្មោះបោះសម្លេងល្បីល្បាញកិត្តិស័ព្ទផ្សាយទៅ ស្ទើរតែគ្រប់ប្រជាជាតិក្នុងពិភពលោក ។ បរិយាយដោយល្អិតទាក់ទងដល់សេចក្តីរុងរឿងរបស់មហាវិទ្យាល័យនាលន្ទា, ពាក្យថា "នាលន្ទា" ជាឈ្មោះចាស់ ឈ្មោះដើមបំផុត ជាប់តមកតាំងពីបុរាណសម័យ ឥតមានផ្លាស់ប្តូរឡើយ ។

នាលន្ទា មានន័យមកពីពាក្យថា "នអលំទា (naalāmdā)" ប្រែថា "ខ្ញុំនឹងមិនឲ្យ" ឬថា "ខ្ញុំមិនអាចឲ្យទៀត" (នៈមិន; អលំ=ល្មមឬអាច, ទា=ឲ្យ) ។ មានប្រវត្តិនិទានថា ក្នុងអតីតកាលព្រះពោធិសត្វបានឧប្បត្តិឡើងជាក្សត្រិយ៍គ្រងរាជសម្បត្តិក្នុងរាជធានីគ្រង់នេះ ព្រះអង្គមានព្រះទ័យប្រកបដោយមេត្តាអាណិតអាសូរក្រៃពេក បានបរិច្ចាគព្រះរាជទ្រព្យដល់ជនទុគ៌តក្រីក្រលំបាក, ធ្វើបុណ្យឲ្យទានអស់កាលជានិច្ច រហូតដល់ពុំមានជនណាមួយឮព្រះអង្គត្រាស់ថា "ខ្ញុំនឹងមិនឲ្យ" ឬថា "ខ្ញុំមិនអាចឲ្យទៀត" ដូច្នេះឡើយ ។ ន័យមួយទៀតពោលថា "នាលន្ទា" មកពីពាក្យថា "នាល័ននឹងទា;" "នាល័ន" ប្រែថា "ផ្កាឈូក "ទា" ប្រែថា "ឲ្យ" រួមសេចក្ដីថា "ជាទីឲ្យនូវផ្កាឈូក" ព្រោះក្នុងបរិវេណនេះស្របប្រកបដោយផ្កាឈូកច្រើនក្រៃពេក ។ ន័យខ្លះទៀតថា "នាលន្ទា" ជាឈ្មោះរបស់នាគរាជ ដែលនៅអាស្រ័យក្នុងស្រះឈូកចំគ្រង់ទីក្រុងនេះ ក្នុងសម័យបុរាណ ។

សម័យពុទ្ធកាល នាលន្ទាជាកន្លែងរុងរឿងណាស់, ក្នុងព្រះសូត្រមានពោលជាប់ទាក់ទងរឿងរ៉ាវជាច្រើនថាក្នុងតំបន់នេះ មានគេហស្ថានខ្វាត់ខ្វែងជាច្រើនជួរច្រើនសន្ធឹក តាំងនៅពីខាងជើងក្រុងរាជគ្រឹះ ចម្ងាយ១យោជន៍(គឺចំនួន១០គ.ម) ។ មានសេដ្ឋីម្នាក់ឈ្មោះ "លេបា" មានលំនៅកំណើតនៅទីនេះជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ បានថ្វាយទីសម្រាប់ស្រង់ទឹកនិងកន្លែងសម្រាប់សំដែងធម៌ ដល់ព្រះសម្មាសម្ពុទ្ធ សម្រាប់ព្រះអង្គប្រថាប់សំរាកនៅទីនេះឬ នៅបាវារិកម្ពវ័នក៏ជាទីប្រថាប់សំរាកពេល យាងទៅកាន់ក្រុង

ពជគ្រឹះដែរ ។

ជំនាន់មុនពុទ្ធកាល នាលន្ទា ជាស្រុកកំណើតនឹងកន្លែងនៅធ្វើការរបស់អនេលកំឈ្មោះ និគណ្ឋនាដបុត្ត គឺ «មហាវីរៈ» ដែលជាសាស្តារបស់សាសនា ជេន ( Jainism ) មានគោសាល នឹងទីឃតបស្សីជាសាវ័ក ; រហូតដល់បច្ចុប្បន្នសម័យនេះ ក៏ជាកន្លែងពិសេសមួយរបស់ពួកសាសនាជេននោះដែរ ( មានវត្តរបស់សាសនាជេន ពីរកន្លែងជិតមហាវិទ្យាល័យនាលន្ទា ) ។

មហាវិទ្យាល័យបុរាណ

លោកអ្នកអានគង់បានជ្រាបហើយ អំពីការកត់ត្រាទុកក្នុងប្រវត្តិសាស្ត្ររបស់លោកសង្ឃចិនឈ្មោះ ហៀន-ឆាង ( Hiuen - Tsing ) នឹងអ៊ី-ស៊ីង ( I-Tsing ) នឹងអំពី ( Taranath «3 Histong» ) ប្រវត្តិ



គំនរមហាវិទ្យាល័យនាលន្ទាបុរាណ ដែលមានកេរ្តិ៍ឈ្មោះក្នុងប្រទេសឥណ្ឌា
NALANDĀ

សាស្ត្រ ដែលតែងឡើងដោយអ្នកប្រាជ្ញជាតិទីបេក៏ម្នាក់ ឈ្មោះតារនាថ „ ពោលចំពោះរឿងនេះថា ព្រះចៅអសោកមហារាជ ជាអគ្គសាសនូបត្ថម្ភក៏ទ្រង់បានសាងព្រះចេតិយ ព្រះស្តូបទុកជាច្រើននៅកន្លែងនេះ ៗ តមក ព្រះចៅផែនដី កនិករាជវង្ស “ គុប្តៈ „ ( gupta ) មានព្រះបាទស័កាទិត្យៈ, ពុទ្ធគុប្តៈ តថាគតគុប្តៈ , ពាលាទិត្យៈ , កុមារគុប្តៈ ទីងវជ្រៈ ទ្រង់បានស្ថាបនាព្រះវិហារ ទីង

សង្ឃារាមជាច្រើន តាមទំនៀមទម្លាប់ប្រពៃណីក្នុងសម័យនោះ ៗ បរិវេណនៃមហាវិទ្យាល័យនេះធំទូលាយក្រៃពេក មានព្រះវិហារ , ធម្មសភា, ព្រះស្តូប ព្រះចេតិយ តាំងនៅជាជួរបណ្តោយតាមគ្រឹស្ថានសិក្សា ៗ ឯគ្រឹស្ថានសិក្សាមាន ១០ ខ្នង សង់ជាប់គ្នាជាជួរបណ្តោយពីខាងជើង ទៅត្បូងៗ គ្រឹស្ថានមួយ ៗ មានទំហំ៥០ ម. ខ្វះ ៦០ ម. ខ្វះ, ជាង៦០ ម. ខ្វះ ខាងក្នុងគ្រឹស្ថាន មានបន្ទប់



រូបជិណាលព្រះសិអារ្យ
NĀLANDĀ
Maitreya, the Future Buddha
Bronze; medieval
នាលន្ទា

ដេក, បន្ទប់ទឹក, បន្ទប់បន្ក្រាន, បន្ទប់រៀន, បណ្ណាល័យ, អណ្ដូងទឹក និងបង្គន់ សឹងដូចគ្នាគ្រប់ ៗ គ្រឹស្ថាន ៗ បន្ទប់មួយ ៗ មានល្វែងធំទូលាយគួរដល់សុខភាពនិងជាទីរមណីយដល់អ្នក សក្ការ ៗ ពីខាងលិចផ្លូវគ្រឹស្ថានមានព្រះស្ដូប, ព្រះចេតិយធំ ៗ សាងអំពីថ្ម និងប្រកបដោយក្បូរក្បាច់ចម្លាក់អំពីថ្ម ៗ

(នៅមានត)

## រឿងតុក្កតាធ្វើពីទជាតិ (តពីឆ្នាំ ១៩៥៥)

### សេចក្ដីខាបនៃព្រះនាងទុក្ខានី

ស្វាក៏នាំចូលមកកាន់ខ្ទមព្រះនាងទុក្ខានី, ដែលព្រះនា កំពុងតែមានទឹកនេត្រាហូរស្រោកលើព្រះធរណី, ហើយក៏ក្រាបថ្វាយបង្គំព្រះនាងទូលថា

សូមព្រះមាតាទ្រង់ទ មករកខ្ញុំ តើខ្ញុំបានអ្វីយកមកថ្វាយព្រះមាតា! ព្រះមាតាមានត្រឹមតែខ្សែក ដែលដោតខ្ទមបន្ទប៉ុណ្ណោះ មិនសមស័ក្ដិជារាជិនីហើយជាអគ្គមហេសីនៃមហាក្សត្រក្នុងវង្សទៀតផង សូមព្រះមាតាយកខ្សែកនោះចេញ ហើយយកខ្សែកគុជខ្យងដែលជាវត្ថុសមគួរនេះប្រដាប់វិញចុះ ៗ

ព្រះនាងកាលបើទ្រង់ទតខ្សែកគយមុត (Gaya-Motis) នៅនឹងដៃស្វាហើយក៏មានបន្ទូលសួរថា:

ឱ! ស្វា! ឯងបានខ្សែកនេះមកពីណា? ខ្សែកនេះជាព្រះរាជទ្រព្យព្រះមហាក្សត្រទេតើព្រះមាតានេះឯងហើយ ដែលពីអតីតកាល បានយកគុជខ្យងមកក្រងធ្វើជាខ្សែកនេះ... តើឯងបានពីណាមក? តើព្រះមហាក្សត្រធ្វើឲ្យបាត់ឬបោះចោល? តើឯងរើសខ្សែកនេះនៅតាមផ្លូវឬ? ចូរប្រាប់មាតាមក

"ទេ! ព្រះមាតា" ស្វាឆ្លើយ "ខ្ញុំមិនបានរើសនៅតាមផ្លូវទេ ហើយព្រះមហាក្សត្រ ព្រះអង្គមិនមែនបោះបង់ចោលនូវកម្រងគុជខ្យង ដែលព្រះមាតាបានក្រង់ឡើយ"

— បើដូច្នោះមានតែឯងលួចខ្សែកនេះមក? តើលួចពីទីណា? ក្នុងក្រឡាព្រះបន្ទំព្រះអង្គឬ?

— ទេ! ព្រះមាតា ស្វាមានសភាពដូចទូលព្រះបង្គំមិនអាចប្រព្រឹត្តបទលួចបានទេ! គឺពិតជាអំណោយនៃសេចក្ដីត្រេកអររបស់ព្រះមហាក្សត្រតែម្យ៉ាង ព្រោះខ្ញុំព្រះអង្គបានថ្វាយដំណឹងល្អមួយដល់ទ្រង់ ដែលនាំឲ្យទ្រង់ព្រះរាជទានខ្សែនេះមក ។

— ទេ! ស្វា! ឯងរស់នៅជានិច្ចលើក្បាលដង្គន់នៃស្ត្រីមានសេចក្ដីព្រួយលំបាក, តើឯងបានដំណឹងល្អដូចម្ដេចបានជាទៅក្រាបទូលព្រះមហាក្សត្រតាំងពីបុព្វណ្ហសម័យដូចនេះ?

— ព្រះមាតា! ទូលព្រះបង្គំយល់សប្តិឃើញព្រះអនុជតូចមួយ ដែលនាំឲ្យទូលព្រះបង្គំដឹងច្បាស់ថា ព្រះមាតានឹងប្រសូត្រព្រះរាជបុត្រមួយព្រះអង្គ ដែលជាវរជ្ឈាយាទ ហើយបានគ្រងរាជសម្បត្តិក្នុងកាលជាអនាគត ទើបទូលព្រះបង្គំត្រេកអរពីកាយរត់ពាសពេញក្នុងព្រះរាជមន្ទីរ ច្រៀងថ្វាយព្រះមហាក្សត្រថា:

"ទុក្ខរាទី ព្រះទេពី ព្រះទ័យស្មោះ ទ្រង់ចោលសោះ លែងសោកស្ដួរ មាននិស្ស័យ នឹងបានបុត្រ កែវសសុទ្ធិ កបថ្វាថ្លៃ គ្រងបច្ច័យ រាជបញ្ចាង់ អនាគត"

ព្រះមហាក្សត្រមានព្រះទ័យត្រេកអរខ្លាំងពេក ទាល់តែដោះខ្សែកព្រះរាជទានមកឲ្យទូលព្រះបង្គំ ។

(នៅមានត)

# ជ័យប្រាជ្ញ (តពីឆ្នាំ ១៩៥៥)

គ្រូបំបាប់ក៏ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រទៅផ្ទះរបស់ខ្លួនវិញ ។ លុះទៅដល់ផ្ទះហើយ ពួកសិស្សបំបាប់ទាំងប៉ុន្មាន ចូលមកសួរនាំពីហេតុគេចសព្វគ្រប់ ។ គ្រូបំបាប់ក៏បានរៀបរាប់តាមដំណើរ ដែលខ្លួនបានដឹងឮឃើញដល់សិស្សបំបាប់ទាំងឡាយ ។ ពួកសិស្សកាលបើបានឮហេតុដូចនោះហើយ ក៏ចេះតែរៀបរាប់តគ្នាទៅទៀត ៗ អ្នកបំបាប់ដទៃ កាលបើបានឮដំណឹងនេះហើយ ចេះតែមានសេចក្តីស្ញើចព្រឺព្រួចអស្ចារ្យក្នុងចិត្តយ៉ាងខ្លាំង ដោយយល់ថា លោកគ្រូយើងមិនដែលលេងចាញ់នរណាម្នាក់ណាឡើយ ឥឡូវគ្រាន់តែឃើញកូនគេ ក៏ញ័រសាច់ទៅហើយនោះ ប្រហែលជាអ្នកបំបាប់ព្រះមហាក្សត្រ មានសភាពអស្ចារ្យប្រាកដមែន ទើបព្រះអង្គហ៊ានផ្សាយឲ្យយើងរើសជើងឯក យកទៅផ្គូលេងថ្វាយទតយ៉ាងនេះ ណ្ហើយយើងទាំងឡាយមិនបាច់ទៅអើតក្បាលទៀតទេ បើលោកគ្រូយើង សុខចិត្តចាញ់គេពីចម្ងាយដូចនេះទៅហើយ ។ ការរៀបរាប់គ្នារបៀបនេះក៏ផ្សាយទូទៅពេញព្រះរាជអាណាចក្រទាំងមូល ។

ក្នុងថ្ងៃនោះព្រះមហាក្សត្របានចាត់អាមាត្យ ឲ្យចេញទៅស៊ើបសួររកអ្នកបំបាប់គ្រប់ទិសទីតំបន់ក្នុងព្រះរាជអាណាចក្រ តែពុំឃើញមានជនណាមួយអាចឆ្លើយឈ្មោះ ដើម្បីតស៊ូយកជ័យជំនះពីកុមារជ័យបានឡើយ បើទុកណាជាក្រុមអាមាត្យ បានពន្យល់ប្រាប់សេចក្តីពិតយ៉ាងណាក៏ដោយ ក៏នៅតែមិនបានផលអ្វីឡើយ ដោយអ្នកបំបាប់

ទាំងនោះដឹងច្បាស់ក្នុងចិត្តថា:

១– អ្នកបំបាក់របស់ព្រះមហាក្សត្រ មិនដែលមានសភាពទន់ខ្សោយដូចអាមាត្យមកឃោសនាពន្យល់នោះទេ ។

២–បើមិនជាចេះតែប្រថុយតាមព្រេងសំណាងទៅ ខ្លួនមិនដឹងជាត្រូវទទួលគ្រោះថ្នាក់បែបណាទេ ។

៣– បើអ្នកបំបាក់របស់ព្រះអង្គមិនពូកែ មិនមែនឲ្យយើងរើសយកជើងឯកទៅលេងថ្វាយទតទេ ។

៤– ធម្មតាព្រះមហាក្សត្រម្ដេចក៏ព្រះអង្គ ព្រមចាញ់យើងជាពស្ដ្រក្រោមល្អងធូលីព្រះបាទ ។

៥– ថាបើជ័យប្រាជ្ញជាអ្នកបំបាក់ម្ដេចក៏មិនដែលឮថាលេងបំបាក់ម្ដងណាសោះ ថែមទាំងជ័យប្រាជ្ញនោះសោតជាកូនក្មេងទៀតផង មិនសមបើព្រះអង្គទទួលតាំងជាអ្នកបំបាក់របស់ទ្រង់ឡើយ ។ រឿងនេះបើយកមកពិចារណាយកសេចក្ដីពិតវិញ ឃើញថាត្រូវយើងនិយាយពិតជាងអាមាត្យ ។ បំណែកខាងអាមាត្យទាំងឡាយ ដែលចេះតែនិយាយយ៉ាងនេះ ព្រោះតែគេចង់ឲ្យយើងទៅលេងថ្វាយព្រះមហាក្សត្រ ដើម្បីការគាប់គុណរបស់គេប៉ុណ្ណោះ ។ ឯរូបយើងវិញក៏ត្រូវទទួលការស្លាប់ផ្ទាល់ខ្លួន ចំពោះល្បែងនេះ ម្ដេចឡើយនឹងមានគេមកអាណិតអាសូរដល់យើងផង បើលោកត្រូវយើងវិញទើបគាត់អាណិតមេត្តាយើងមែន ៗ បានជាគាត់អាចប្រាប់សេចក្ដីពិតត្រង់ដល់ពួកយើង ។ ហេតុនេះយើងនៅផ្ទះល្អជាងទៅទទួលគ្រោះថ្នាក់ដែលបានដឹងមុនរួចទៅហើយ ។

(នៅមានត)

# បុណ្ណកុមារ (ត)

« តែបិតាបានឮថា នាយទាហានដែលកូនឯងចាប់ខ្លួនបានមកនេះ មានថ្វីខ្លាំងពូកែណាស់ ព្រោះបានសម្លាប់នាយទាហានរបស់យើងស្លាប់ច្រើននាក់ណាស់ហើយ ទាហាន ! នាំវាចូលមកជិតអញ ! អញចង់មើលមុខវាឲ្យច្បាស់ណាស់ ហើយចង់ដឹងណាស់ថា តើក្នុងកាលដែលវាជិតនឹងដល់ពេលដែលត្រូវកាត់ក្បាលនោះ វានៅតែក្លាហានដូចដែលវានៅក្នុងទីសមរភូមិដែរឬអី ? »

បុណ្ណមាណពត្រូវគេដឹកដៃដែលជាប់ចំណង ឲ្យចូលទៅជិតព្រះរាជបល្ល័ង្ក ។ ខណៈនោះព្រះសូរសៀងទទាន ដែលសំដែងនូវការស្ងុតព្រះទ័យ ក៏កើតឡើងចំពោះព្រះរាជា ព្រោះព្រះអង្គបានទតឃើញរង្វង់មុខដ៏ឆ្នងលក្ខណៈ ទាំងអស់របស់នាយទាហាន នៃទេវគិរីនគរយ៉ាងជាក់ច្បាស់ ព្រមទាំងគ្រាប់ផ្កាំពីរគ្រាប់ ដែលបុណ្ណមាណពពាក់ជាប់នៅកផងនោះ ។

សត្យាទរៈកុមារ ( នាយទាហានដែលប្រយុទ្ធគ្នាជាមួយបុណ្ណមាណពអម្បាញ់មិញនេះ ) ទ្រង់យាងចូលមកជិតហើយចាប់គ្រាប់ផ្កាំពិនិត្យមើលដោយការងឿងឆ្ងល់ ។

« ឯងជានរណាឈ្មោះអី ? »

ព្រះរាជាត្រាស់សួរ « ហេតុអ្វីក៏មានផ្កាំបែបនេះពាក់នៅកដូច្នេះ ឯងបានពីណាមក ? »

« ទូលព្រះបង្គំឈ្មោះបុណ្ណៈ កាន់តំណែងជាមេបញ្ជាការកងទ័ពសេះនៃទេវគិរីនគរ គ្រាប់ផ្កាំនេះជារបស់ទូលព្រះបង្គំផ្ទាល់ខ្លួន កាលពី

ដើមមាន ៤ គ្រាប់ ”

“ ឯងបានមកពីណា ? ”

“ ទូលព្រះបង្គំបានមកពីជីតា របស់ទូលព្រះបង្គំ ដែលឥឡូវនេះគាត់អនិច្ចកម្មទៅហើយ ”

“ ជីតារបស់ឯងឈ្មោះអី ? ”

“ ទូលព្រះបង្គំមិនស្គាល់ឈ្មោះគាត់ទេ ព្រោះគាត់អនិច្ចកម្មទៅតាំងពីពេលដែលទូលព្រះបង្គំនៅក្មេងមិនទាន់ដឹងក្ដី ”

“ ចុះគ្រាប់ផ្កាំ ២ គ្រាប់ទៀតនោះ ឯងទុកនៅឯណា ? ”

“ ទូលព្រះបង្គំទុក...ទុកនៅឯទេ-វគិរីនគរ...”

ព្រះបាទសត្យរាជទ្រង់នៅស្ងៀម ដោយទ្រង់រំសម្លឹងទតបុណ្ណមាណព ហើយពិចារណាយ៉ាងពិនិត្យពិច័យ ក្នុងទីបំផុតព្រះអង្គទ្រង់ត្រាស់បង្គាប់ថា

“ ទាហាន ! ចូរដោះគាវចេញឆាប់ ! ”

នៅពេលដែលដោះគាវចេញភ្លាម ព្រះរាជាព្រមទាំងបរិវារទាំងអស់ ក៏បានឃើញផ្ចកខ្មៅប៉ុនមេដៃ នៅក្រោមដោះខាងឆ្វេងនៃបុណ្ណមាណព ហើយក៏ឧទានឡើងទាំងអស់គ្នា ដោយការស្លុតចិត្តថា

“ សត្យយុទ្ធា!... ព្រះរាជកុមារ!...”

បុណ្ណមាណពដូចជាទឹកធ្លាក់ក្នុងចិត្តយ៉ាងខ្លាំង ដែលឃើញព្រះរាជាស្រក់ព្រះជលនេត្រ ហើយស្ទុះចុះពីរាជបល្ល័ង្កចូលមកឱបរឹតខ្លួន ព្រមទាំងទ្រង់មានព្រះរាជបន្ទូលរអាក់រអួល ជាមួយនឹងខ្លួនថា

“ សត្យយុទ្ធា! សត្យយុទ្ធាកូនសម្លាញ់ ! ឪពុកបានជួបនឹងកូនហើយ ! ”

បុណ្ណមាណពបានឃើញរង្វង់ព្រះភក្ត្រនៃព្រះរាជាស្រដៀងនឹងមុខខ្លួន

គេគិតថា «អញជាកូនស្ដេចទេដឹង តែឱ ! នឹងទៅជាដូច្នោះបានឬ ? ដែលអញមកក្លាយខ្លួនទៅជាព្រះរាជឱរស របស់ព្រះរាជា នៃកល្យាណីបុរៈនគរ នេះ » បុណ្ណមាណពជឿខ្លះ មិនជឿខ្លះ... តែក្នុងទីបំផុតសញ្ញាតិញាណនៃខ្សែលោហិតរវាងឪពុកនឹងកូន បានកើតឡើងយ៉ាងឆាប់រហ័ស បុណ្ណមាណពយល់ជាក់ថា បុគ្គលដែលកំពុងតែឱបរឹតខ្លួនហើយយំខ្សឹកខ្សួលនេះ នឹងមិនមែនជាអ្នកណាដទៃក្រៅពីឪពុករបស់ខ្លួនឡើយ ហើយបុណ្ណមាណពក៏ឧទានឡើងតិចថា

« ព្រះបិតាសម្លាញ់របស់កូន ! »

ហើយឈរស្រឡាំងកាំងដូចជាបុគ្គលដែលគ្មានស្មារតីក្នុងរង្វង់ព្រះកររបស់ព្រះរាជានៃកល្យាណីបុរៈនគរនុ៎ះឯង ។

សត្យយុទ្ធា ព្រះរាជកុមាររបស់ព្រះបាទសត្យរាជដែលបានបាត់ខ្លួនពីព្រះនគរទៅកាលពីជាង២០ឆ្នាំមកហើយ ក៏គឺបុណ្ណកុមារនោះឯង ។ ក្រោយពេលមានស្មារតីដឹងខ្លួនមកវិញហើយ ព្រះរាជាក៏ទ្រង់បរិយាយឲ្យស្ដាប់ថា

កូនឯងត្រូវព្រះបិតុលាគិតការក្បថ ដោយមានបំណងចង់ដណ្ដើមយកព្រះរាជបល្លង្គនៃកល្យាណីបុរៈនគរ បានលួចនាំយកបាត់ទៅ តាំងពីកូនឯងអាយុ ២ឆ្នាំ គ្រាដែលកងទ័ពក្បថបានបាក់បែកទៅ ព្រះបិតុលាឯងគេចខ្លួនបាត់ទៅគ្មានលេចឮដំណឹងអ្វីសោះ សត្យយុទ្ធារាជកុមារក៏បាត់ខ្លួនសូន្យទៅជាមួយដែរ មិនដឹងជាស្លាប់ឬរស់យ៉ាងណា ហើយគ្រាប់ផ្គាំ៤គ្រាប់នេះជាគ្រឿងតែងកាយព្រះរាជកុមារតាំងពីតូចៗមក ហើយជាប្រវេណីនៃកល្យាណីបុរៈនគរដែលព្រះរាជកុមារគ្រប់ៗ ព្រះអង្គរបស់ព្រះរាជានឹងត្រូវពាក់គ្រាប់ផ្គាំ៤គ្រាប់ ដែលបានសែកមន្តអាគម ដោយរាជគ្រូប្រចាំ

ខ្លួនជានិច្ចហើយការដែលបុណ្ណមាណព បានឃើញនូវគ្រាប់ផ្គាំពាក់ នៅករបស់ គូប្រយុទ្ធនៃខ្លួនក្នុងសមរភូមិនោះ ក៏ ព្រោះអ្នកនោះជាព្រះរាជបុត្ររបស់ព្រះ រាជាដែលត្រូវជាប្អូនរបស់បុណ្ណមាណព ទុះឯង ៗ (នៅមានត)

## ប្រវត្តិក្មេងកំព្រា (ត)

សម្រាប់ជីវិតដ៏អភ័ព្វរបស់បងបែប នេះ បងស៊ូៗថយចាកក្រុមមកពួនសម្ងំ តែម្នាក់ឯង ហើយនឹងសម្លាប់ខ្លួនដោយ ថ្នាំអាសិរពិសតែម្ដង,, មាត់បេះតែនិ- យាយរាងកាយរបស់នាយ ក៏ថយចេញ ពីរង្វង់ដៃនាង ហើយក៏យកថ្នាំមកផ្សៀ នៅទីបំណោះនាងមួយរំពេច; កាលបើ ផ្សំហើយ នាយក៏និយាយតទៅទៀត ថា

“ ឥឡូវនេះអូនបានមកដល់ជម្រំ របស់បងហើយ បងសូមប្រគល់វត្ថុទាំង អស់នេះទុកឲ្យអូន, ចូរអូនហៅសំ- ណាងឲ្យមកដឹករបស់ទាំងនេះយកទៅ ថ្វាយព្រះមហាក្សត្ររបស់យើង ព្រោះ សុទ្ធតែជារបស់មានដម្លៃ ហើយកម្រក បានទៀត ៗ របស់ទាំងនេះបងបាន កាលដែលជប៉ុនចុះហត្ថលេខា ស្ងប់សឹក ជាមួយនឹងសហរដ្ឋអាមេរិក ដោយសក្តិ បួនិម្នាក់បានឲ្យមកបង រួមទាំងកាណូត មួយផង ដែលបងលាក់ទុកត្រង់ប្រហោក ថ្មមួយកន្ទុងនៅមាត់សមុទ្រ ដែលមាន ដើមឈើដុសគ្របពីលើជិត ចម្ងាយពីទី នេះប្រហែលជា ៣០០ម ៗ ត្រូវអូនដឹង ថាទីនេះជាកន្លែងជិតមាត់ទឹក ហើយជា កន្លែងស្ងាត់កំបាំងបំផុត មិនមាននណា មួយស្គាល់ឡើយ ៗ

ដើម្បីបំពេញបំណងអូនទៅអនា- គត់ ត្រូវរូបបងរលត់ជីវិតពីលោកនេះ

ទៅ ព្រោះបងមិនអាចធ្វើអំពើអាក្រក់អ្វីមួយដល់អូនបានឡើយ ៗ អូនដឹងបានទេ! ហេតុអ្វីបានជាបងមិនហ៊ានរំលោភលើសេរីភាពអូនយូរណាស់មកហើយ! ពិតណាស់អូន! គួរពិចារណាមើល! បើបងរំលោភលើសេរីភាពអូន តើអូនអាចចៀសវាងបានដែរ បើអូននៅក្នុងកណ្ដាប់ដៃបងទៅហើយ ៗ តែថានេះជាឧត្តមគតិ របស់បុរសស្នេហាជាតិសុទ្ធ ៗ ហើយមិនតែប៉ុណ្ណោះសោតរូបអូនទៀតក៏ត្រូវជាប្អូនរបស់បងជីដូនមួយបង្កើតដែរ លោកដន្ទើប្រសើរឪពុករបស់អូនត្រូវជាប្អូនឪពុកបងបង្កើត តែបងមិនហ៊ាន ប្រាប់សេចក្ដីពិតត្រង់នេះដល់អូនទេ ៗ តែឥឡូវត្រូវបងប្រាប់អូនឲ្យអស់មុននឹងបងស្លាប់„ មាត់បេះតែនិយាយដៃក៏កាន់កែវថ្នាំជាប់ ៗ នាងដោយកំពុងតែសំរក់ទឹកភ្នែក ក្នុងរឿងនេះ ក៏នាងពុំបានចាប់ភ្លឹកដល់ថ្នាំដែលនៅនឹងដៃនាយឡើយ ចេះតែប្រុងប្រៀបនឹងស្ដាប់តទៅទៀត តែស្រាប់តែបាត់សំដីនាយក្នុងពេលនោះ ភ្លាមតែម្ដង ៗ

នាងក៏ភ្ញាក់ខ្លួនព្រើតងើបមុខមើលនាយភ្លាម ស្រាប់តែឃើញបែរខ្នងមករកនាង ហើយលើកកែវថ្នាំផឹកតែម្ដង

"ឈប់បង„ នាងស្រែកឡើងព្រមទាំងទះដៃដែលកាន់កែវថ្នាំឲ្យជ្រុះ តែពិតមែនជាកែវធ្លាក់មកប៉ះនឹងថ្មបែកកំពុបថ្នាំខ្ចាត់ខ្ចាយអស់ក៏ដោយ ក៏គង់ជាតិពុលចូលដល់ពោះអ្នកខ្លះទៅហើយដែរ ៗ

នាងក៏ស្ទុះឱបនាយវិន្ទា ហើយយកក្បាលទៅផ្ទប់នឹងដើមទ្រូង នាយពោលរអាក់រអួលថា "បង! បងវិន្ទាបងស្អប់ប្អូនណាស់ទៅឬ? បានជាធ្វើយ៉ាងនេះ! បងដឹងដែរថា អូនជាប្រដាប់សម្រាប់ជីវិតបងទៅអនាគត, អូន

នឹងរៀបការជាមួយបង, អូនដឹងហើយថាបងសំណាង គេស្រឡាញ់អូនមែនតែគេស្រឡាញ់ក្នុងឋានៈជាប្អូនបង្កើត ហើយរូបគេក៏មានសង្សារួចទៅហើយផង ៗ ម្ដេចក៏បងមិនយល់ចិត្តអូន! បើសិនជាអូន មិនមានសេចក្ដីស្នេហាលើបងប្រហែលជាមិនប្រថុយដើរតាមបងទាំងរាត្រីងងឹត ដែលមិនមាននរណាមួយដឹងឮសោះនោះទេ, ចុះបើបងធ្វើយ៉ាងនេះ តើឲ្យអូននៅទីពឹងលើរូបអ្នកណា! ឱ! បង! ជីវិតអូននឹងស៊ូស្លាប់ជាមួយបងក្នុងថ្ងៃនេះមិនខាន បើសិនជាបងត្រូវថ្នាំអាសិរពិសនេះស្លាប់ៗ

នាងញ័រ... ញ័រខ្លួនប្រាណដោយឃើញនាយវិន្ទាញញឹមចុបនាងដោយថ្នមៗ នឹងយកប្រមុះមកដាក់ជិតថ្ពាល់របស់នាង តែខណៈជាមួយគ្នានេះនាយក៏ទន់ខ្លួនមួយរំពេច ធ្វើឲ្យនាងទ្រពងកាយបុរសមួយ ស្ទើរពុំឈ្នះ ហើយក៏ប្រឹងកៀកពងកាយ ដ៏ធ្ងន់នេះយកមកដាក់លើគ្រែ

នាយវិន្ទា មិនមាននិយាយអ្វីទៀតឡើយ ភ្នែកនាយបិទជិតឈឹងដូចជាបុគ្គលស្លាប់ យូរៗឃើញនាយបើកភ្នែកម្ដង ដែលមានរង្វង់ភ្នែកពោរពេញដោយទរនៃដលនេត្រ សរឲ្យឃើញថានាយកំពុងសោកស្រណោះអាឡោះអាល័យនាង ដោយមិនមានសង្ឃឹមថានឹងមានជីវិតរស់នៅដើម្បី សាងសេចក្ដីសុខឲ្យនាងទៅអនាគតបានឡើយ ៗ

(នៅមានត)

រោងពុម្ពទរិយ
នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥